# សកម្មភាពសំខាន់ និងចំបង ដែលទាក់ទងនឹង សុខភាព និងសុវត្ថិភាពការងារ



សេចក្តីប្រកាសរួមដោយលោក XAVIER HUILLARD ដែលជាប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិរបស់ក្រុមហ៊ុន VINCI និងក្រុមប្រឹក្សាការងារអឺរ៉ុប

# សុខភាព និងសុវត្ថិភាពការងារ៖ ចូលរួមទាំងអស់គ្នា ដើម្បីធ្វើសកម្មភាព



# ការប្តេជ្ញាចិត្តចំណុចទី ៥ នៃសេចក្តីថ្លែងការណ៍របស់ក្រុមហ៊ុន VINCI ។ រួមគ្នា! ខិតខំប្រឹងប្រែងសម្រាប់អត្រាគ្រោះថ្នាក់សូន្យ

## សេចក្តីប្រកាសរួមដោយលោក Xavier Huillard ដែលជាប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិរបស់ក្រុមហ៊ុន VINCI និងក្រុមប្រឹក្សាការងារអឺរ៉ុប។

ការប្តេជ្ញាចិត្តចំពោះគោលបំណងអត្រាគ្រោះថ្នាក់សូន្យ គឺជាចំណុចសំខាន់នៃសេចក្តីថ្លែងការណ៍របស់ក្រុមហ៊ុន VINCI ។ សេចក្តីប្រកាសនេះ ត្រូវបានរៀបចំជាមួយក្រុមប្រឹក្សាការងារអឺរ៉ុបរបស់ក្រុមហ៊ុន VINCI Group ដែលបង្ហាញពីការប្តេជ្ញាចិត្តរួមគ្នារបស់យើងដើម្បីសម្រេចគោលដៅ។

គោលបំណងរបស់យើង គឺដើម្បីផ្តល់នូវក្របខណ្ឌយោងមួយពីសកម្មភាពសំខាន់និងចំបង ដែលត្រូវអនុវត្តដោយធ្វើតាមសកម្មភាព និងធ្វើការវិភាគដោយក្រុមហ៊ុនរបស់ VINCI Group ទាក់ទងនឹងសុខភាពនិងសុវត្ថិភាព និងការទប់ស្កាត់ហានិភ័យក្នុងការងារ។

វាបញ្ជាក់អោយឃើញ ពីការចែករំលែកនូវភាពជឿជាក់របស់យើង ដែលជំរុញអោយមានការចូលរួមពីនិយោជិតទាំងអស់ និងអ្នកតំណាងរបស់ពួកគេ តាមរយៈការលើកកម្ពស់សុវត្ថិភាពរបស់យើង។

Rueil-Malmaison ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៧

**Xavier Huillard**
ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកប្រតិបត្តិ
ក្រុមហ៊ុន VINCI



**Noureddine Boudjeniba**
លេខាធិការក្រុមប្រឹក្សាការងារអឺរ៉ុប



# ចូលរួមទាំងអស់គ្នា ដើម្បីធ្វើសកម្មភាព

សុខភាពនិងសុវត្ថិភាពការងារ គឺជាកង្វល់របស់និយោជិតទាំងអស់ ហើយនិយោជិតទាំងអស់ត្រូវតែចូលរួម។

អ្នកគ្រប់គ្រងទាំងអស់ ត្រូវតែធានានូវសុខភាព និងសុវត្ថិភាពរបស់និយោជិតស្ថិតនៅក្រោមទំនួលខុសត្រូវរបស់ខ្លួន។ បណ្ដាញសុខភាពនិងសុវត្ថិភាព មានអ្នកជំនាញដែលអាចជួយអ្នកគ្រប់គ្រង តាមជំហានដែលត្រូវធ្វើ។

បុគ្គលិកទាំងអស់ ដោយមិនគិតពីអតីតភាពការងាររបស់ពួកគេ ត្រូវតែថែទាំសុខភាព និងសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេ ក៏ដូចជា សុខភាពនិងសុវត្ថិភាពរបស់មនុស្សរួមការងារជាមួយគេផងដែរ។

និយោជិត ត្រូវយល់ដឹងពីដំណើរការប្រតិបត្តិ និងបទបញ្ជាសុវត្ថិភាព ហើយគោរពតាមបទបញ្ជាទាំងនោះ។ សម្ភារៈនិងឧបករណ៍ ត្រូវប្រើតាមការណែនាំ ហើយឧបករណ៍ការពារផ្ទាល់ខ្លួន ត្រូវតែពាក់អោយបានត្រឹមត្រូវ។

នៅពេលដែលនិយោជិតសង្កេតឃើញស្ថានភាពដែលគំរាមកំហែងដល់សុខភាព និងសុវត្ថិភាព ត្រូវរាយការណ៍ជូន និយោជក ឬថ្នាក់លើជាបន្ទាន់។ និយោជិកមិនត្រូវមានការរិះគន់ពីការរាយការណ៍ប្រភេទនេះនោះទេ។

**ដើម្បីអោយមនុស្សប្រើជំនាញទាំងអស់ដែលគេមាន មកធ្វើការច្នៃប្រឌិត និងមានការ ប្ដេជ្ញាចិត្ត ដើម្បីធ្វើអោយសុខភាពនិងសុវត្ថិភាព ជាមួយនឹង បរិស្ថានការងារមានភាពប្រសើរឡើង ហើយទង្វើរទាំងនោះ គួរទទួលបានការលើកទឹកចិត្ត និងអាចទាញយកផលប្រយោជន៍ ដើម្បីលើកកម្ពស់វប្បធម៌ចែករំលែក ទាំងក្នុងក្រុមហ៊ុន និងក្រៅក្រុមហ៊ុន។**



## កិច្ចសហការជាមួយអ្នកតំណាងបុគ្គលិក

អ្នកតំណាងបុគ្គលិកនៃអង្គភាពនីមួយៗ ជាភាគីពាក់ព័ន្ធសំខាន់ ដែលត្រូវទទួលបានព័ត៌មានតម្លាភាព អំពីសកម្មភាពដែលត្រូវធ្វើ ដើម្បីកែលម្អលក្ខខណ្ឌការងារ ហើយដើម្បីការពារគ្រោះថ្នាក់ឧប្បត្តិហេតុនៅកន្លែងធ្វើការ និងហានិភ័យការងារ។ ពួកគេគួរតែត្រូវបានលើកទឹកចិត្តអោយធ្វើសំណើទាក់ទងនឹងសកម្មភាពនេះ។

# សកម្មភាពសំខាន់ និងចំបង

សកម្មភាពទាំងនេះ ត្រូវតែអនុវត្តនៅគ្រប់វិស័យទាំងអស់របស់ក្រុមហ៊ុន។




## សកម្មភាពទាំងនេះ នឹងធ្វើអោយប្រសើរឡើង នូវលទ្ធផលសុខភាពនិងសុវត្ថិភាព ដែលត្រូវបានអនុវត្តតាមបទបញ្ញត្តិ។

### ការវិភាគហានិភ័យ

ការវិភាគអំពីហានិភ័យដែលទាក់ទងទៅ នឹងស្ថានភាពការងារទាំងអស់ គួរតែវិភាគអោយបានមុនតាមដែលអាចធ្វើទៅបាន ដែលក្នុងនោះរួមមាន បរិយាកាសការងារ ដំណើរការប្រតិបត្តិ ឧបករណ៍និងសម្ភារៈដែលត្រូវបានប្រើប្រាស់ ជាដើម ទើបការគ្រប់គ្រងទៅលើ សុខភាពនិងសុវត្ថិភាពការងារ មានប្រសិទ្ធភាព។

### ឧបករណ៍ការពារផ្ទាល់ខ្លួន

គ្រប់អង្គភាពទាំងអស់ គួរតែផ្តល់ជូនបុគ្គលិករបស់ខ្លួន នូវឧបករណ៍ការពារផ្ទាល់ខ្លួន ដោយឥតគិតថ្លៃ ដែលស្របតាមស្ថានភាពការងារនីមួយៗ ហើយស្របតាមតម្រូវការដែលកំណត់ដោយប្រទេសដែលពាក់ព័ន្ធ ព្រមទាំងជួយការពារ សុខភាពនិងសុវត្ថិភាពរបស់បុគ្គលិក ប្រកបដោយប្រសិទ្ធិភាព។

### និតិវិធីប្រតិបត្តិការ ដំណើរការ និងការរៀបចំការងារ

និតិវិធីប្រតិបត្តិការ និងដំណើរការ គួររួមបញ្ចូល វិធានបង្ការហានិភ័យ ដែលអាចកើតមានឡើង។ ក្រុមហ៊ុន VINCI Group ត្រូវតែរៀបចំការងារ ដើម្បីលើកកម្ពស់សុខភាពនិងសុវត្ថិភាពបុគ្គលិក។

### ការយល់ដឹងអំពី សុវត្ថិភាព និងការបណ្តុះបណ្តាល

ដើម្បីធានានូវកម្រិតនៃការការពារ គ្រប់អង្គភាពទាំងអស់ត្រូវទទួលខុសត្រូវក្នុងការបង្កើនការយល់ដឹង ដោយផ្តល់ព័ត៌មានដល់បុគ្គលិកទាំងអស់ ពីហានិភ័យដែលទាក់ទងនឹងសកម្មភាពការងាររបស់ពួកគេ និងវិធានការចាំបាច់ ដើម្បីកាត់បន្ថយឬលុបបំបាត់ហានិភ័យទាំងនោះ។
និយោជិត ត្រូវទទួលបានការបណ្តុះបណ្តាល អំពីសុខភាព និងសុវត្ថិភាពការងារក្នុងម៉ោងធ្វើការ ផ្តល់ការណែនាំ និងការពន្យល់យ៉ាងជាក់លាក់ ទាក់ទងនឹង តួនាទីឬភារកិច្ចរបស់ពួកគេ។
ការថែទាំពិសេស គួរធ្វើដើម្បីធានាថា កម្មករនិយោជិតទាំងអស់ដែលធ្វើការក្នុងក្រុមហ៊ុន VINCI Group មានការយល់ដឹងពីសេចក្តីណែនាំស្តីពីសុវត្ថិភាព។

# ការតាមដានសកម្មភាព និងការវិភាគ

### អ្នកនៅក្នុងវិស័យនេះទាំងអស់ ត្រូវតែចូលរួមជាមួយគ្នា

គោលនយោបាយ អគ្រោះថ្នាក់សូន្យ គឺអនុវត្តចំពោះបុគ្គលិករបស់ក្រុមហ៊ុន VINCI បុគ្គលិកបណ្តោះអាសន្ន និងអ្នកខាងក្រៅផងដែរ ដែលត្រូវទទួលបានអត្ថប្រយោជន៍ ពីលក្ខខណ្ឌសុវត្ថិភាពដូចបុគ្គលិកទូទៅ។ ដោយសារការប្តេជ្ញាចិត្តនេះហើយ ទើប ក្រុមក្រុមហ៊ុនទាំងអស់ចូលរួមជាមួយអ្នកម៉ៅការ ដើម្បី កែលម្អវិធានការរបស់ពួកគេ។

### ការអភិវឌ្ឍន៍គោលនយោបាយសុខភាពការងារ

អង្គភាពទាំងអស់ គួរប្តេជ្ញាធ្វើអោយប្រសើរឡើង នូវលក្ខខណ្ឌការងារ បូករួមទាំងការរៀបចំការងារ ដើម្បីអោយមានភាពងាយស្រួល និងធ្វើអោយប្រសើរឡើង នូវគុណភាពនៃជីវិត នៅកន្លែងធ្វើការ ជាពិសេស តាមរយៈការទប់ស្កាត់ហានិភ័យ ផ្លូវចិត្តនិងសង្គម។

# ការត្រួតពិនិត្យលទ្ធផល និងការចែករំលែកព័ត៌មាន

លទ្ធផលនៃសកម្មភាព ត្រូវបានវាស់ ដោយប្រើសូចនាករដែលពាក់ព័ន្ធ ដើម្បីសម្រេចបាននូវការរីកចម្រើនប្រកបដោយនិរន្តរភាព។ សូចនាករទាំងនោះ ត្រូវបានបង្ហាញ និងពិភាក្សា ដូច្នេះសកម្មភាពដែលចាំបាច់ដើម្បីកែលម្អលទ្ធផល អាចត្រូវបានអនុវត្ត។

គ្រោះថ្នាក់នីមួយៗ ត្រូវតែពិនិត្យអោយបានហ្មត់ចត់ និងមានវិធីសាស្រ្តច្បាស់លាស់ នៅក្នុងក្រុមហ៊ុន ដោយសហការជាមួយតំណាងបុគ្គលិកផងដែរ។ លើកទឹកចិត្តអោយមាន ការកំណត់អត្តសញ្ញាណស្ថានភាពដែលមិនមានសុវត្ថិភាព និងគ្រោះថ្នាក់ដែលជិតមកដល់ អាចជួយកាត់បន្ថយចំនួនគ្រោះថ្នាក់ និងជាពិសេសជួយកសាងវប្បធម៌នៃសុវត្ថិភាពប្រចាំថ្ងៃ។

ជាទូទៅការប្រកាសនេះ មានគោលបំណងដើម្បីផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងរូបភាពទាំងអស់ នៃសុខភាព និងសុវត្ថិភាពការងារ និងដើម្បីក្រើនរំលឹកដល់គ្រប់គ្នា អំពីគុណសម្បត្តិនៃការចែករំលែកនូវការអនុវត្តន៍និងមតិដែលជួយជម្រុញអោយមានភាពប្រសើរឡើងជាបន្តបន្ទាប់។

# ការអនុវត្តន៍សេចក្តីប្រកាស

ដោយយោងតាមរដ្ឋបាលវិមជ្ឈការរបស់ក្រុមហ៊ុន និង ដើម្បីសម្របតាមជំហាននៃស្ថានភាពក្នុងតំបន់ ការប្តេជ្ញាចិត្តស្តីពី សុខភាពនិងសុវត្ថិភាព ត្រូវបានកំណត់ និងអនុវត្ត នៅក្នុងអង្គភាពអាជីវកម្មនីមួយៗ ដើម្បីលើកកម្ពស់និងកែលម្អ។

អ្នកគ្រប់គ្រង ត្រូវទទួលខុសត្រូវចំពោះការអនុវត្តន៍ជាក់ស្តែងនៃគំនិតផ្តួចផ្តើម ដើម្បីលើកកម្ពស់ សុខភាពនិងសុវត្ថិភាព តាមរយៈកម្មករនិយោជិតនៅក្នុងតំបន់របស់ពួកគេ។

សុខភាពនិងសុវត្ថិភាពការងារ តោះចូលរួមទាំងអស់គ្នា!

យោងតាមកិច្ចព្រមព្រៀងក្រុមប្រឹក្សាការងារអឺរ៉ុបរបស់ក្រុមហ៊ុន VINCI របាយការណ៍ប្រចាំត្រីមាស ត្រូវបញ្ជូនទៅការិយាល័យរបស់ក្រុមប្រឹក្សាទទួលបន្ទុកគ្រោះថ្នាក់នៅកន្លែងធ្វើការ គ្រោះថ្នាក់ចរាចរណ៍ និងជម្ងឺដែលកើតដោយការងារ ។

សេចក្តីប្រកាសនេះ ត្រូវបានបកប្រែជាភាសារបស់ប្រទេសទាំងអស់ ដែលជាតំណាងក្រុមប្រឹក្សាការងារអឺរ៉ុប ដូច្នេះ វាអាចចែកចាយយ៉ាងទូលំទូលាយទៅកាន់ក្រុមហ៊ុនដែលស្ថិតនៅក្រោមក្រុមហ៊ុន VINCI Group ទាំងអស់។



គោលបំណងរបស់យើង៖
គឺដើម្បីលើកកម្ពស់
វប្បធម៌នៃសុខាភិបាល
និងសុវត្ថិភាពការងារ។

ជោគជ័យពិតប្រាកដ
គឺជាជោគជ័យដែលយើង
ចែករំលែកជាមួយគ្នា។

បោះពុម្ពផ្សាយនៅថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០១៧ - SST-2017-06-KH – ឥណទានរូបថត: Yves Chanoit – Axel Herse – Stéphanie Jayet – VINCI និង ក្រុមរូបថតក្រុមហ៊ុនបុត្រសម្ព័ន្ធ និង DR ។ – ការរចនា៖ www.gcommeuneidee.com

**VINCI**
1, cours Ferdinand-de-Lesseps
F–92851 Rueil-Malmaison Cedex
ទូរស័ព្ទ៖ + 33 1 47 16 35 00
**www.vinci.com**